# វិទ្យាស្ថាន តស៊ូមតិ និងគោលនយោបាយ
# វេទិកាពិគ្រោះយោបល់ស្តីពី
# សិទ្ធិទទួលព័ត៌មាន
# ២០១០

## សេចក្តីផ្តើម និងប្រវត្តិ

វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ យល់ថាសិទ្ធិទទួលព័ត៌មានជាផ្នែកមួយដ៏សំខាន់សំរាប់លើកស្ទួយសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ នៅខែធ្នូ ឆ្នាំ ២០០៤ រាជរដ្ឋាភិបាលកម្ពុជាបានសន្យាអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន អោយបាននៅឆ្នាំ ២០០៦ ប៉ុន្តែរហូតដល់ពេលនេះនៅតែមិនបានសម្រេចតាមសន្យានៅឡើយ។ ក្រោយមកនៅខែសីហា ឆ្នាំ ២០០៧ មានជំនួយបច្ចេកទេសពីទីភ្នាក់ងារសហរដ្ឋអាមេរិកសំរាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ **USAID** តាមរយៈ អង្គការផេកកម្ពុជា និងក្រុមការងារមកពីអន្តរក្រសួងដែលដឹកនាំដោយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច (MONASRI) បានបញ្ចប់សេចក្តីព្រាងឯកសារគោលនយោបាយ ស្តីពីសិទ្ធិទទួលព័ត៌មាន ។ ដោយមានការគាំទ្រពីអង្គការសមាជិកក្រុម ការងារសិទ្ធិទទួលព័ត៌មាន (FOI) វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ (API) កំពុងតែស្ថិតក្នុងឱកាសដ៏ល្អមួយ ដើម្បីធ្វើការលើបញ្ហានេះ ព្រោះ API ជាអង្គការមួយដែលមានបទពិសោធន៍តស៊ូមតិនិងបានចូលរួមជាមួយក្រុមការងារ សិទ្ធិទទួលព័ត៌មានក្នុងការផ្តល់ជំនាញ បច្ចេកទេសផ្សេងៗ និងស្វែងរកជំនួយដើម្បីជំរុញដោះស្រាយបញ្ហានេះបន្តទៀត។

រហូតមកដល់ពេលនេះមិនទាន់មានព័ត៌មានណាចង្អុលបង្ហាញពីការអនុម័តសេចក្តីព្រាងឯកសារគោលនយោបាយស្តីពីសិទ្ធិទទួលព័ត៌មាន។

យោងតាមរបាយការណ៍នៃវេទិកាពិគ្រោះយោបល់ ស្តីពីសិទ្ធិទទួលព័ត៌មានចំនួន៩លើក ក្នុងខេត្តចំនួន ៩ ដែលធ្វើឡើងដោយក្រុមការងារសិទ្ធិទទួលព័ត៌មាននៅឆ្នាំ ២០០៨-២០០៩ ដែលមានអ្នកចូលរួមចំរុះគ្នាពីស្ថាប័នរដ្ឋ ស្ថាប័នឯកជន អង្គការសង្គមស៊ីវិល សាស្ត្រាចារ្យ និស្សិត និងសហគមន៍ យើងឃើញថាមានសំណូមពរ ជាច្រើនស្នើឱ្យមានច្បាប់ស្តីពី សិទ្ធិទទួលព័ត៌មាន បង្កើនយន្តការបើកចំហព័ត៌មាន ជាពិសេសបង្កើនការផ្សព្វផ្សាយពីសិទ្ធិទទួលព័ត៌មានឱ្យដល់សហគមន៍។

ដូច្នេះដើម្បីធ្វើវេទិកាពិគ្រោះយោបល់ស្តីពីសិទ្ធិទទួលព័ត៌មាននៅ២០១០ឱ្យកាន់តែមានប្រសិទ្ធភាព ក្រុមការងារមានគម្រោងនិងគោលបំណងសហការរៀបចំវេទិកាពិគ្រោះយោបល់ជាមួយក្រសួងទំនាក់ទំនង ជាមួយរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច (MONASRI) និងអង្គការពាក់ព័ន្ធនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ដោយផ្តោតលើក្រុមគោលដៅជាក់លាក់ ដើម្បី បង្កើនចំណេះចំណេះដឹងថ្មីពីសិទ្ធិទទួលព័ត៌មាន ប្រមូលអនុសាសន៍ជាក់លាក់ពី អង្គការសង្គមស៊ីវិល សហគមន៍

លើវិស័យនិមួយៗជុំវិញការបង្កើតច្បាប់ដើម្បីទទួលបានចំណេះដឹងបន្ថែមទៀតពីសេចក្តីត្រូវការ ការទាមទារ និងយោបល់ផ្សេងៗដែលអាចគួរដាក់បញ្ចូលក្នុងសេចក្តីព្រាងច្បាប់នេះ ។

## គោលបំណង

គោលបំណងនៃវេទិការួមមានៈ

- អប់រំផ្សព្វផ្សាយដើម្បីបង្កើនចំណេះដឹងដល់អង្គការសង្គមស៊ីវិលតាមវិស័យនិងប្រជាពលរដ្ឋស្តីពីសិទ្ធិទទួលព័ត៌មាននិងសារប្រយោជន៍នៃសិទ្ធិទទួលព័ត៌មានសំរាប់ការអភិវឌ្ឍន៍សង្គមកម្ពុជា ។
- ស្វែងរក និងប្រមូលសេចក្តីត្រូវការ ការទាមទារ និងយោបល់ឬអនុសាសន៍ផ្សេងៗជាក់លាក់ តាមវិស័យនិមួយៗដែលគួរដាក់បញ្ចូលក្នុងសេចក្តីព្រាងច្បាប់នេះជូនទៅរាជរដ្ឋាភិបាលដើម្បីធ្វើការពិចារណា និងអនុម័តច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានមួយ ដែលឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

## សកម្មភាពនៃវេទិកា

- គណៈកម្មាការមួយត្រូវបានរៀបចំឡើងដោយមាន (API ក្រុមការងារការងារសិទ្ធិទទួលព័តមានអង្គការបណ្តាញពាក់ព័ន្ធតាមវិស័យ)
- គណៈកម្មាការរៀបចំត្រូវមើលខុសត្រូវលើ សន្ទរកថារបស់វាគ្មិន កម្មវិធី លិខិតអញ្ជើញអ្នកចូលរួម និងវាគ្មិនប្រអប់ឈ្មោះគណធិបតីនិងអ្នកសំរបសំរួលកម្មវិធីរៀបចំសម្ភារៈសំណួរសំរាប់ក្រុមពិភាក្សា និងសម្ភារៈសំរាប់ការរៀបចំវេទិកាទាំងមូល (ឧបករណ៍សំរាប់ការបង្ហាញរបស់វាគ្មិន)
- ជួយផ្តល់យោបល់លើប្រធានបទ គោលបំណង ការបរិច្ឆេទសំរាប់វេទិកា
- រៀបចំអាហារសំរន់ និងអាហារថ្ងៃត្រង់ ត្រូវរៀបចំទុកជាមុន
- រៀបចំការថតចំលង និងថតរូបភាពនៃវេទិកា
- សម្របសម្រួលក្រុមពិភាក្សា
- កត់ត្រាកំណត់ហេតុនៃវេទិកា
- រៀបចំអ្នកទទួលខុសត្រូវតាមមុខងារនីមួយៗ
- ធ្វើរបាយការណ៏នៃវេទិកា និងរាយការណ៏ដល់ក្រុមការងារសិទ្ធិទទួលព័ត៌មាន

## លទ្ធផលរំពឹងទុក

វេទិកាពិភាក្សាពិគ្រោះយោបល់នឹងទទួលបានលទ្ធផលដូចខាងក្រោម :

- បង្កើនចំណេះដឹង និងសារសំខាន់ដល់អ្នកចូលរួមលើសិទ្ធិទទួលព័ត៌មាន និងក្របខ័ណ្ឌគោលនយោបាយស្តីពីសិទ្ធិទទួលព័ត៌មាន
- កំណត់បានកំរិតនៃការទទួលបាន និងប្រភេទព័ត៌មានដែលត្រូវការទៅតាមជំនាញនិមួយៗ
- ទទួលបានមតិយោបល់ផ្សេងៗពីអ្នកចូលរួមលើក្របខ័ណ្ឌគោលនយោបាយនិងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន និងផលលំបាកនៃកង្វះព័ត៌មាន ដើម្បីដាក់ជូនទៅក្រសួងសាមី និងរដ្ឋសភា ។

## ប្រធានបទនៃវេទិការពិភាក្សា

- គោលបំណងវេទិកា
- ប្រវត្តិសង្ខេបរបស់ក្រុមការងារសិទ្ធិទទួលព័ត៌មាន
- អ្វីជាសិទ្ធិទទួលព័ត៌មាន និងសារៈសំខាន់របស់វា
- គោលការណ៏សំខាន់ៗទាំង ៩ ក្នុងសេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយ ស្តីពីសិទ្ធិទទួលព័ត៌មាន
- បទបង្ហាញនៃវិស័យនិមួយៗទាក់ទងទៅនិងព័ត៌មាន
- ករណីសិក្សាទៅតាមជំនាញនិមួយៗ ប្រសិនបើមាន

## សំណួរក្រុមពិភាក្សា

**លើកទី១:**

- <u>**សំណួរទី១**</u> សិទ្ធិទទួលព័ត៌មានជាសិទ្ធិរបស់មនុស្សគ្រប់រូបក្នុងការទទួលបានព័ត៌មានពីស្ថានសាធារណៈទាំងឡាយ ហើយសិទ្ធិនេះត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់ ។

  ១ តើព័ត៌មានអ្វីខ្លះដែលលោកអ្នកចង់ដឹង និង ត្រូវការ ពីឃុំ-សង្កាត់ មន្ទីរក្រសួង?
  តើអ្នកមានបានទទួលព័ត៌មានទាំងអស់នេះដែរឬទេ?

  ២ តើលោកអ្នកមានការលំបាកអ្វីខ្លះនៅពេលទៅសុំព័ត៌មានពីស្ថាប័នទាំងនោះ?
  តើលោកអ្នកបានធ្វើអ្វីខ្លះពេលអ្នកជួបការលំបាកទាំងនេះ?

- **លើកទី២:** ការមានសិទ្ធិទទួលព័ត៌មាន និងការទទួលបានព័ត៌មានគឺសំខាន់ណាស់សម្រាប់ការរស់នៅរបស់យើងម្នាក់ៗ:

  ១ តើអ្នកយល់ថារាជរដ្ឋាភិបាលគួរធ្វើអ្វីខ្លះដើម្បីឱ្យយើងទទួលបានព័ត៌មានគ្រប់គ្រាន់?

  ២ តើមានគំនិតយោបល់ ឬចំនុចអ្វីខ្លះ ដែលអ្នកចង់ឱ្យមាននៅក្នុងច្បាប់នេះដើម្បីបំពេញទៅនឹងសេចក្តីត្រូវការរបស់យើងទាំងអស់គ្នា?

## អ្នកចូលរួម

វេទិកានេះនឹងធ្វើឡើងទៅតាមក្រុមជាក់លាក់និមួយៗដាច់ដោយឡែកពីគ្នាដើម្បីកំណត់បាននូវព័តិមានជាក់លាក់តាមវិស័យនិមួយៗ ដូចខាងក្រោមៈ

- ក្រុមអ្នកសារព័តិមាន
- សហជិបកម្មកររោងចក្រ
- មន្រ្តីរាជការ
- អង្គការសង្គមស៊ីវិល
- សាស្ត្រាចារ្យ និងនិស្សិត
- សមាគមន៏កសិករ
- សមាគមន៏ពាណិជ្ជករ និងអាជីវករ

វេទិកានឹងមានអ្នកចូលរួមយ៉ាងច្រើន ៦0 នាក់ ( ស្រី ៣0 នាក់) ។

**ស្ថាប័នអនុវត្តន៍** វេទិការពិភាក្សានឹងរៀបចំដោយ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) សហការ ជាមួយសមាជិកអង្គការបណ្តាញនិងស្ថាប័នពាក់ព័ន្ធតាមវិស័យ ។ល ។) ។ គណៈកម្មការរៀបចំវេទិកាពិភាក្សានឹងត្រូវបង្កើតដោយ មានសមាជិក ៤ឬ៥រូប ដើម្បីទទួលខុសត្រូវត្រួតពិនិត្យលើដំណើរការរៀបចំ ក្នុងនោះមានតំណាងពីវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយចំនួន ១-២រូប សមាជិកក្រុមការងារសិទ្ធិទទួលព័តិមាន ១រូប តំណាងក្រសួងជំនាញ ១រូប ( បើមាន) និងតំណាងអង្គការដៃគូ ១ រូប ។ យើងសង្ឃឹមថាគណៈកម្មការនឹងធ្វើការពិគ្រោះយោបល់ជា ប្រចាំជាមួយវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ ។